# ការសំភាសន៍របស់អ៊ុំស្រី មាស សូហាយ

កៈ អ្នកដែរសំភាសន៍គេ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍មាស សូហាយ

## <u>ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី មាស សូហាយ</u>

អ៊ុំស្រី មាស សូហាយ មានអាយុ53ឆ្នាំ នៅក្នុងឆ្នាំ2018អ៊ុំស្រី មាស សូហាយ មាន ភេទស្រី

អ៊ុំស្រី មាស សូហាយ មានទីលំនៅបច្ចុប្បន្ននៅភូមិស្វាយរលំ ឃុំស្វាយរលំ ភូមិមួយ ស្រុកស្អាង ខេត្តកណ្ដាល។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ អត់មានប៉ះពាល់អីទេណ?

កៈ អត់មានប៉ះពាល់អីទេ

ខៈ សំភាសន៍ពីជំនាន់ពលពតអីចឹងហាសណាស់

កៈ បាទអ៊ុំចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី22 ខែ2 ឆ្នាំ2018 ហើយធ្វើឡើងនៅភូមិស្វាយរលំ ឃុំស្វាយរលំ គេហៅភូមិមួយណាអ៊ុំ?

ខៈ នៅភូមិមួយ

កៈ នៅស្រុកស្អាង ខេត្តកណ្ដាល ចឹងសំរាប់អ៊ុំមានឈ្មោះរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  មានឈ្មោះថា មាស សូហាយ

ក៖  ឈ្មោះមាស សូហាយ មានឈ្មោះហៅក្រៅដែរទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះអំអីផ្សេងដែរទេអ៊ុំ?

ខ៖  ហៅយាយហាច

ក៖  ហៅយាយហាចណាអ៊ុំ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖  អាយុ58ឆ្នាំ

ក៖  ចឹងអ៊ុំអាយុ58ឆ្នាំ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖  កើតនៅថ្ងៃទី15 ខែ4 ឆ្នាំ1960

ក៖  អូ៎!នៅឆ្នាំ1960 ចុះអ៊ុំឆ្នាំច័ន្ទគតិអ៊ុំឆ្នាំអីគេដែរអ៊ុំ ឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ុំ?

ខ៖  ឆ្នាំជូត

ក៖  ឆ្នាំជូតហោសអ៊ុំ ចុះអ៊ុំកើតនៅណាដែរអ៊ុំចងចាំទេ នៅភូមិ ឃុំ ស្រុកអី?

ខ៖  (ស្តាប់មិនសូវបានទេ) ភូមិស្អាមអង្កាល ស្រុកគគរ នៅខេត្តពោសាត់

ក៖  អូ៎!អ៊ុំកើតនៅខេត្តពោសាត់ហោសអ៊ុំ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖  មានបងប្អូនចំនួន2នាក់នឹង អូមាន3នាក់ប៉ុន្តែស្លាប់នៅជំនាន់ពលពតមួយ

ក៖  ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖  មានស្រីម្នាក់ នឹងប្រុសពីរនាក់

ក៖  ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖  ខ្ញុំជាកូនកណ្តាលកូនទីពីរ

ក៖ ចុះអ្នកដែរស្លាប់នឹងគាត់ជាបងរបស់អ៊ុំរឺក៏ប្អូនរបស់អ៊ុំដែរ?

ខ៖  គាត់បងខ្ញុំ

កៈ ចុះហេតុអីបានជាគាត់ស្លាប់ដែរអ៊ុំ?

ខៈ អត់បាយ កាលពីជំនាន់អាពតនឹងគាត់មិនមានអីហូបនឹងគាត់ហើមស្លាប់ទៅ

កៈ ប៉ុន្តែអ៊ុំមិនអីទេកាលណុង?

ខៈ អ៊ូ!ហើមដែរនឹងបិះៗៗនឹងស្លាប់ដែរនឹងហាស

កៈ ចុះហេតុអីបានជាអ៊ុំផុតអ៊ុំ?

ខៈ កាលណុងចេះចេះតែទ្រាំហូទៅស្លឹកឈើ ស្លឹកព្រៃអីចឹងទៅណាស់ ដូចជាជំឡូងនឹងក្តួចអីយើងចេះ តែដើររកខ្លះទៅណាស់

កៈ បាទអ៊ុំបាទ?

ខៈ នឹងហើយនឹង

កៈ ចុះអ៊ុំគិតថាបងប្អូនរបស់អ៊ុំដែរអ៊ុំប្រាប់មិញនឹងពួកគាត់មានឈ្មោះអីគេខ្លះដែរចឹងហាស បងអ៊ុំមានឈ្មោះ ហើយប្អូនរបស់អ៊ុំមានឈ្មោះអី?

ខៈ ប្អូនរបស់អ៊ុំមានឈ្មោះ មាស ហ៊ុន

កៈ នឹងប្អូនហោសអ៊ុំ?

ខៈ ប្អូននឹងដេកឈឺហើយឥឡូវនឹង

កៈ ចុះបងរបស់អ៊ុំមានឈ្មោះអីគេដែរ?

ខៈ បងមានឈ្មោះ មាស ណុន

កៈ ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅក្មេងៗៗជាមួយពួកគាត់ដែរទេអ៊ុំ អ៊ុំធ្លាប់បានធ្វើអីគេជាមួយពួកគាត់ដែរចឹងហាស?

ខៈ រៀនពួកខ្ញុំរៀនចេញពីរៀនរៀងខ្លួនកាលណុងនៅតូចចឹងរៀនរៀងខ្លួន

កៈ
បាទអ៊ុំចូលរៀនហើយពេលដែរចេញពីរៀនហើយអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីដើរលេងជាមួយគាត់ លក្ខណៈលេងបិទពួន រឺលេងឡឹកបាយឡអីចឹង?

ខ៖ មកផ្ទះយើងធម្មតានឹង

ក៖ លេងអីគេខ្លះដែរអ៊ុំអាចប្រាប់បានទេ?

ខ៖ លេងដូចជាលេងឃ្លីលេងអីចឹងទៅណាស់ លេងបាយខំអីនឹង

ក៖ អូ៎!អ៊ុំចេះលេងឃ្លីទៀត?

ខ៖ លេងបាញ់ឃ្លីកាលពីនៅតូចៗនឹងកាលនៅក្មេងៗហោស

ក៖ បាទអ៊ុំចុះអ៊ុំគិតថាអ៊ុំចូលចិត្តលេងអីជាមួយពួកគាត់ដែរអ៊ុំ?

ខ៖ គាត់ធំជាងខ្ញុំឆ្ងាយជាងខ្ញុំ ចឹងខ្ញុំនៅតូចៗៗលេងបិទពួនជាមួយប្អូនរបស់ខ្ញុំនឹង

ក៖ អូ៎!បាទអ៊ុំ ចុះប្អូនរបស់អ៊ុំគាត់នៅណាដែរអ៊ុំឥឡូវនឹង?

ខ៖ នៅពោសាត់ហោស

ក៖ គាត់ធ្វើអីគេដែរនៅណុងអ៊ុំ?

ខ៖ នៅផ្ទះឈឺនៅលីវហាស

ក៖ អូ៎!ឥឡូវនឹងគាត់នៅលីវហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយចាស់ហើយ

ក៖ ប៉ុន្តែគាត់មិនយកប្តីទេហោសអ៊ុំ?

ខ៖ ឈឺឡើងស្គមនឹងវាបាក់វាតាំងពីនៅជំនាន់អាពតនឹង

ក៖ ប៉ុន្តែគាត់នៅណុងតែម្នាក់ឯងមែនអ៊ុំ?

ខ៖ នៅជាមួយបងប្អូននឹង

ក៖ អូ៎!ចុះម្តាយរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់មានឈ្មោះមី ហេង

ក៖ ចុះគាត់អាយុប៉ុន្មានដែរអ៊ុំមានចងចាំទេ?

ខ៖ 
អ៎ូ!អត់ដឹងទេនឹងភ្លេចបាត់ហើយកាលពីគាត់ស្លាប់នឹងអាយុហាជាងនឹងគាត់ស្លាប់នៅឆ្នាំ197
7

ក៖ វាជិត40ឆ្នាំហើយចឹងវាចង់មួយរយឆ្នាំជាងហើយណអ៊ុំ?

ខ៖ ខ្វង់ប៉ែតរឺក៏កៅហើយនឹង

ក៖ គាត់ហាជាងឥឡូវនឹង?

ខ៖ គាត់អាយុ52-53ឆ្នាំហើយគាត់នឹង

ក៖ នឹងហើយចូលកៅសិបឆ្នាំជាងហើយអ៊ុំ ចុះកាត់កើតនៅណាអ៊ុំមានដឹងទេ?

ខ៖ គាត់កើតនៅកន្លែងភូមិ ឃុំ ខ្ញុំនឹងហាសនៅដដែរនឹងភូមិ ឃុំតែមួយនឹង

ក៖ ចុះម្ដាយរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះមី ហោង

ក៖ ចុះឪពុកវិញអ៊ុំ?

ខ៖ ឈ្មោះមាស ម៉ន

ក៖ ចុះឪពុករបស់អ៊ុំកាលពីគាត់នៅរស់ ប៉ុន្តែគាត់ស្លាប់បាត់ហើយមែនទេអ៊ុំ?

ខ៖ គាត់ស្លាប់នៅជំនាន់ពលពត

ក៖ ប៉ុន្តែឪពុករបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជិវិតដែរអ៊ុំ?

ខ៖ គាត់ធ្វើស្រែនឹង

ក៖ គាត់ធ្វើស្រែហោស ចុះគាត់ស្លូត រឺមួយក៏កាចដែរអ៊ុំ?

ខ៖ គាត់ស្លូតណាស់គាត់ធ្វើស្រែហើយគាត់ធ្វើជាអាចារ្យផងនឹង

ក៖ បាទចុះម្ដាយរបស់អ៊ុំគាត់ធ្វើអីគេដែរ?

ខ៖ ម្ដាយនៅផ្ទះគាត់ដាំបន្លែ គាត់ស្ទូងស្រូវចិញ្ចឹមគោអោយកូនរៀន

កៈ ចុះគាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ គាត់កាចដែរគាត់កាចល្មមនឹង

កៈ ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយពួកគាត់ដែរចឹងហាស?

ខៈ គ្មានធ្លាប់ធ្វើអីទេ គាត់ធ្លាប់តែប្រើដាំបាយដាំទឹកអីនឹង
ជួយយកស្រូវយកអង្ករអីមកទុកដាក់អីចឹងទៅ ស្រួលគាត់បោកបែនអីចឹងទៅណាស់

កៈ បាទអ៊ុំចុះឪពុករបស់អ៊ុំគាត់មានដែរប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ គាត់បួសរហូតពីក្មេងមកនឹង

កៈ អូ៎!ចុះម្តាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងអីទៅអ៊ុំដែរទេ?

ខៈ ម្តាយរបស់ខ្ញុំនឹងគាត់ដូចជាគ្មានអីទេ
គាត់ដូចថាគាត់រៀនកាត់ដេរជាមួយមីងគាត់អីចឹងហាសណាស់

កៈ បាទមីងបាទចឹង?

ខៈ នឹងហើយដល់ពេលដែរយូរទៅគាត់មិនរៀនកាត់ដេរគាត់មកផ្ទះវិញ

កៈ អូ៎!កើតអីអ៊ុំ?

ខៈ គាត់ថាអាណិតម៉ែឪគាត់អត់មាននរណាជួយធ្វើអីចឹងហាសណាស់

កៈ បាទអ៊ុំ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ យាយតាខាងឪពុកតាមាសនឹង ហីមែនទេ ឈ្មោះតាម៉ម

កៈ ចុះយាយវិញ?

ខៈ អត់ដឹងទេ

កៈ ចុះយាយតាខាងម្តាយវិញអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ដឹងថាយាយណៃ តាសួរ

កៈ ឈ្មោះតា សួរ នឹងយាយណៃ ចុះអ៊ុំមកនៅនឹងយូរនៅអ៊ុំ?

ខ៖  ថាម៉េច?

ក៖  អ៊ុំមកនៅខេត្តនឹងយូរនៅ?

ខ៖  ខ្ញុំមកនៅតាំងឆ្នាំ1983ហោស

ក៖  ឆ្នាំ1983ចឹងមានន័យថាអ៊ុំមកនៅនឹងអស់35ឆ្នាំហើយណា?

ខ៖  ចាំ!នឹងហើយ

ក៖  ចុះអ៊ុំមានកូនចៅ រឺមួយបងប្អូនណាដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  ចឹងនៅតែនឹងទេ?

ខ៖  ចាំ!នៅនឹង

ក៖  ចុះស្វាមីរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  មានឈ្មោះឈុំ ឈឿន

ក៖  ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេអ៊ុំ?

ខ៖  នៅថ្ងៃទី10 នៅឆ្នាំប៉ុន្មានទេនេះខែ2នឹង

ក៖  នៅខែ2ហោសអ៊ុំ?

ខ៖  នៅថ្ងៃ10 ខែ2 ឆ្នាំ1985

ក៖  នៅឆ្នាំ1985 ចឹងអ៊ុំការបានប្រហែលជាបាន35ឆ្នាំហើយណាអ៊ុំ?

ខ៖  ចាំ!នឹង

ក៖
អូ!ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍គិតថាអ៊ុំជាអ្នកចិត្តចង់រៀបដោយខ្លួនឯងរឺមួយឪពុកម្ដាយជា អ្នកចិត្តរៀបអោយដែរអ៊ុំ?

ខ៖  ឪពុកម្ដាយនឹងមីងមាយើងកំព្រានោះនឹងប្រធានអង្គភាពនឹង

កៈ ចុះមានថ្លៃជំនូនទេពេលដែរអ៊ុំប្រុសចូលមកស្ដីដណ្ដឹងចឹងហាស?

ខៈ មានមួយជីមាស

កៈ អ្ហ៎!បានមាសមួយជីហោសអ៊ុំ?

ខៈ មាសបានមួយជីនឹង

កៈ ចុះអ៊ុំអាចប្រាប់ខ្ញុំបានទេថាអ៊ុំជួបជាមួយពូនៅពេលណា
ហេតុអីបានជាគាត់ស្រលាញ់អ៊ុំចឹង?

ខៈ ធ្វើការជាមួយគ្នាហើយមេៗគាត់ទៅផ្សំផ្គុំអោយចឹងទៅណាស់

កៈ ប៉ុន្តែអ៊ុំចាប់អារម្មណ៍គាត់ដែរតើហីអ៊ុំកាលពីជំនាន់ណុង?

ខៈ ទេគ្មានដឹងអីទេកាលពីជំនានណុងហោស
គេផ្សំផ្គុំអោយយើងយើងក៏ព្រមតាមគាត់ចឹងទៅណាស់

កៈ ប៉ុន្តែខាងអ៊ុំក៏អូខេដែរ?

ខៈ នឹងហើយមានអីធ្វើការជាមួយគ្នានឹងយើងចាស់ៗដែរហើយនឹង

កៈ បាទអ៊ុំចឹង?

ខៈ អាយុ25ឆ្នាំហើយនឹង

កៈ ចុះអ៊ុំចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខៈ ចេះធម្មតានឹង

កៈ ចេះធម្មតាណាអ៊ុំ?

ខៈ លក្ខណៈចេះធ្វើការកើតនឹង

កៈ ចុះអ៊ុំបានរៀននៅថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខៈ ថ្នាក់ទី5នឹងពីសង្គមនឹង

កៈ ចុះកាលពីអ៊ុំរៀននឹងអ៊ុំរៀនសាលានៅណាដែរអ៊ុំ?

ខ៖  រៀននៅសាលាលីសេក្រគរ

ក៖  នៅណាវិញអ៊ុំ?

ខ៖  លីសេក្រគរកាលណុងគេអីទេកាលពីដើមនឹងនៅលើលីសេក្រគរនឹង

ក៖  ប៉ុន្តែនៅខេត្តណាដែរអ៊ុំ?

ខ៖  នៅខេត្តពោសាត់

ក៖  នៅខេត្តពោសាត់ ចុះស្រុកអីគេ?

ខ៖ នៅស្រុកក្រគរ អានឹងវិទ្យាល័យហាស ឥឡូវនឹងមកវិទ្យាល័យហើយ អនុវិទ្យាល័យ

ក៖  ចុះបឋមសិក្សាវិញអ៊ុំ?

ខ៖  ដឹងអីកាលណុងរៀនជ្រៅដែរនឹងហាស
ចុះសាលាលីសេកាលណុងគួរសមដែរនឹងហាស

ក៖  បាទអ៊ុំចុះអ៊ុំធ្លាប់មានមិត្តភក្តិដែរស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ
កាលពីនៅក្មេងៗហាស?

ខ៖  មានដែរប៉ុន្តែឥឡូវនឹងបែកស្លាប់មិនដឹងថាទៅណាទេនឹង

ក៖  ប៉ុន្តែអ៊ុំអាចរៀបរាប់ឈ្មោះមួយចំនួនដែរអ៊ុំចងចាំបានទេអ៊ុំ?

ខ៖  មិនដឹងថាឈ្មោះណាទេ ឈ្មោះលៃហៀងមួយ
ឈ្មោះស្អីទេស្លាប់នៅជំនាន់អាពតអស់ហើយនឹង

ក៖  អ៎ូ!បាទចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយពួកគាត់ដែរទេអ៊ុំ?

ខ៖  ទៅរៀនជាមួយគ្នានឹង

ក៖  ធ្លាប់ទៅធ្វើអីគេខ្លះជាមួយគ្នាដែរអ៊ុំ?

ខ៖
ទៅលេងហូបចុកដើរដូចថាចេញលេងអីជាមួយគ្នាចឹងទៅពិភាក្សាអីជាមួយគ្នាចឹងទៅណាស់

កៈ  បាទអ៊ុំបាទ?

ខៈ  ទន្ទេញមេរៀនជាមួយគ្នាដើរអីជាមួយគ្នាចឹងទៅណាស់

កៈ  ចុះអ៊ុំគិតថាអ៊ុំធ្លាប់ទៅធ្វើស្រែចំការទេអ៊ុំ?

ខៈ  ណាគេ?

កៈ  អ៊ុំធ្លាប់ទៅធ្វើស្រែចំការទេអ៊ុំ?

ខៈ  ធ្វើតើនឹង

កៈ  អ៊ុំធ្វើអីគេដែរនៅស្រែចំការនឹងអ៊ុំ?

ខៈ  កាលយើងនៅតូចហោស
គ្មានធ្វើអីឪពុកម្ដាយធ្វើស្រែយើងជួយគាត់តិចតួចនឹងចឹងទៅណាស់

កៈ  ចុះអ៊ុំធ្លាប់បង្កើតអាជីវកម្មលក់ដូរអីទេអ៊ុំ?

ខៈ  អត់ទេ

កៈ  ចុះអ៊ុំមានធ្លាប់ដូចជាចិញ្ចឹមសត្វដូចជាចិញ្ចឹមគោ មាន់ ទា ជ្រូក ក្របីអីទេ?

ខៈ  ចិញ្ចឹមគោឪពុកម្ដាយចិញ្ចឹមគោនឹង

កៈ  ចិញ្ចឹមច្រើនរឺមួយក៏ចិញ្ចឹមតិចអ៊ុំ?

ខៈ  ចិញ្ចឹមច្រើនដែរនឹងហាសចិញ្ចឹម20ក្បាលអីនឹង

កៈ  អូ៎!លលក្ខណៈចង់ក្លាយជាកសិដ្ឋានហើយនឹងអ៊ុំចឹង?

ខៈ  នឹងហើយចិញ្ចឹមនោតាមវាលស្រែនឹង

កៈ  អូ៎!បាទអ៊ុំ
ចុះអ៊ុំគិតថាអ៊ុំធ្លាប់ការងារអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ  ពីដើមនឹងខ្ញុំគ្មានធ្វើអីទេខ្ញុំនោរៀនដល់ពេលឥឡូចនឹងខ្ញុំធ្វើជាពេទ្យទាហ៊ាននឹង

កៈ  អូ៎!បាទអ៊ុំ?

ខ៖  ខ្ញុំធ្វើជាពេទ្យទាហ៊ានតាំងពីឆ្នាំ1983មកនឹងហាស

ក៖  អូ៎!បាទអ៊ុំ
ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាសជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរចឹងហាសអ៊ុំ?

ខ៖  មានការផ្លាស់ប្តូរផ្លាស់ពីមានទៅក្រ ផ្លាស់ពីក្រទៅមានចឹងហាសរកស៊ីខាតអស់

ក៖  ប៉ុន្តែឥឡូវនឹងអ៊ុំធូរជាងមុនហើយណាអ៊ុំ?

ខ៖  អត់ទេតឹងជាងមុន

ក៖  អូ៎!តឹងជាងមុនហោសអ៊ុំ?

ខ៖  រកស៊ីខាតអស់ហើយ ចាញ់បោកគេអស់ហើយនឹង

ក៖  អូ៎!ម៉េចចឹងអ៊ុំ?

ខ៖  រកស៊ី(ស្តាប់អត់បានទេ)រកស៊ីលុយ

ក៖  អូ៎!មីងអ្នកដាក់លុយអោយគាត់ហោសមីង?

ខ៖ នឹងហើយយើងមិនចំណាប់នឹងយើងមិនចេះដេរនឹងហាស តែចិត្តធិមយកមិនបានទេ

ក៖  អូ៎!បាទអ៊ុំ ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖  ប្រហុក ផ្អក ស្លម្ជូរ

ក៖  អូ៎! ចុះតាំងពីក្មេងនឹងអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរអ៊ុំ?

ខ៖  អត់ទេនឹង លេងដែរលេងបោះអង្គុញនឹងពីដើមហោស

ក៖  អូ បាទលក្ខណះលេងបោះអង្គុញ ទាញព្រាត លាក់កន្សែងអីនឹងហោសអ៊ុំ?

ខ៖  នឹងហើយលាក់កន្សែងនឹង

ក៖  ចុះអ៊ុំចេះច្រៀងដែរទេអ៊ុំ?

ខ៖  អត់ទេ

កៈ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងទេអ៊ុំ?

ខៈ អត់ចូលចិត្តស្តាប់រឿង

កៈ ប៉ុន្តែល្ខោនយីកេ អាយៃអីអ៊ុំចូលចិត្តទេ?

ខៈ ចូលចិត្តអាយៃរឿងនឹងល្ខោននឹង

កៈ អ៎ូ!ចឹងអ៊ុំចូលចិត្តធិមដែរហោសអ៊ុំ?

ខៈ ចូលចិត្តស្តាប់រាល់យប់នឹង

កៈ ចឹងអ៊ុំចូលចិត្តដែរចឹង?

ខៈ នឹងហើយចូលចិត្តស្តាប់ទាល់តែដេកលក់

កៈ បាទអ៊ុំ ចុះអ៊ុំគិតថាមាននរណានៅក្នុងផ្ទះរបស់អ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខៈ អត់មានទេ

កៈ បងប្អូនជីដូនមួយអីក៏មិនចេះដែរ?

ខៈ អត់ទេអត់មានទេ

កៈ
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះ
ហាស?

ខៈ ធម្មតានឹងផ្ទះក្បឿងធម្មតានឹង

កៈ ចុះកាលពីក្មេងនឹងផ្ទះតូចរឺមួយក៏ផ្ទះធំដែរអ៊ុំ?

ខៈ ធំល្មមនឹង

កៈ ប៉ុន្តែដល់ពេលឥឡូវនឹង?

ខៈ ក៏ល្មមដែរនឹង

កៈ ចុះផ្ទះរបស់អ៊ុំនឹងនរណាគេជាអ្នកធ្វើអ៊ុំជួលគេ រឺមួយក៏អ៊ុំធ្វើដោយខ្លួនឯងដែរ?

ខ៖  ធ្វើដោយខ្លួនឯងនឹង

ក៖  អ៎ូ! នរណាគេចេះធ្វើផ្ទះដែរអ៊ុំ?

ខ៖  ជាងគេនឹងហាសពីដើមនឹងនៅជាមួយឪពុកម្ដាយនឹង

ក៖  ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងគេប្រើឧបករណ៍អីគេខ្លះដែរសំរាប់ធ្វើអ៊ុំ?

ខ៖  មានឈើ ថ្ម ឥដ្ឋនឹង

ក៖  បាទអ៊ុំ ចុះជំនាញអីដែរអ៊ុំស្ទាត់ជំនាញធ្វើដែរអ៊ុំ?

ខ៖  ខ្ញុំហោស?

ក៖  ជំនាញអីដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖  ធ្វើការងារហោស?

ក៖  ទាំងធ្វើការងារទាំងអីនឹងអ៊ុំគិតថាធ្វើអីគេដែរគិតថាចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖  ខ្ញុំគ្មានធ្វើអីទេខ្ញុំមានតែធ្វើពេទ្យនឹងហាស

ក៖  អ៎ូ!បាទអ៊ុំបាទ?

ខ៖  នឹងហើយស្ទាត់ជំនាញរបស់ខ្ញុំហើយនឹងហាស

ក៖  ចុះអ៊ុំគិតថាឪពុកម្ដាយរបស់អ៊ុំនឹងធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំដែរទេ លក្ខណៈថាវេញវល្លិ៍ ធ្វើផ្ដៅ ធ្វើកន្ទេលនឹង?

ខ៖  ធ្វើជាកន្ទេល

ក៖  អ៊ុំចេះធ្វើហោស មាននរណាគេជាអ្នកបង្រៀនអ៊ុំដែរ?

ខ៖  ម្ដាយប៉ុន្តែភ្លេចអស់ហើយឥឡូវនឹងហោស

ក៖  អ៎ូ!កាលណុងអ៊ុំធ្វើនៅស្រុកហោសអ៊ុំ?

ខ៖  នឹងហើយចេះធ្វើតិច ជួយត្បាញតាមគាត់អីចឹងហាសណាស់

ក៖  ចុះអ៊ុំគិតថាកាលពីពលពត នឹងកាលពីក្មេងអ៊ុំធ្លាប់មានជួបការលំបាកអីគេខ្លះដែរអ៊ុំ?

ខ៖ លែងនិយាយហើយថ្លែងមិនបានទេជំនាន់ណុងជំនាន់ពលពតនឹង

ក៖ ប៉ុន្តែកាលពីនៅក្មេងហាស?

ខ៖ កាលពីនៅក្មេងនឹងគេអោយលើកប្រឡាយ
រឺជីប្រឡាយនឹងជីរែកប្រឡាយនឹងមួយថ្ងៃជីអោយបាន30 ម៉ែត្រនឹង បណ្តោយនឹង

ក៖ ចុះអ៊ុំគិតថាកាលពីជំនាន់ពលពតនឹងអ៊ុំធ្លាប់ជួបការលំបាកអីគេខ្លះដែរទៅអ៊ុំ?

ខ៖ លំបាកកាលណុងអត់បាយធ្វើការងារហួសកំលាំងនឹង ហើយស្គមដើរមិនរួចទេ
ជួនកាលទៅដើរឈើ ច្រត់នឹងហាស

ក៖ អូ្ន!ចឹងហោសអ៊ុំ?

ខ៖ ហើមជើង ហើយកដៃតូចៗនឹងហើយ

ក៖ ប៉ុន្តែពេលណុងគេជំលាសអ៊ុំទៅណាដែរអ៊ុំ?

ខ៖ ជួនកាលគេជំលាសមកផ្ទះចឹងមកផឹកថ្នាំអីចឹងទៅ តាមកសិដ្ឋានទៅណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ ដល់ពេលដែរផឹកថ្នាំទៅបានជាខ្លះទៅវិញចឹងទៅទៅសុំស្ករគេស៊ីខ្លះអីចឹងទៅណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ ដល់ពេលដែរជាចឹងទៅវិញទៅនឹង

ក៖ ចុះអ៊ុំគិតថាពេលណុងអ៊ុំជំលាសបានប៉ុន្មានកន្លែងដែរអ៊ុំ?

ខ៖ អូ្ន!បានច្រើនណាស់បានប្រហែលជា4-5-10កន្លែងអីណោះ
មានច្រើនណាស់ជំលាសទៅនេះតិច ទៅនោះតិចចឹងទៅ
ទៅខេត្តប៉ុន្តែនៅខេត្តពោសាត់នឹង

ក៖ ប៉ុន្តែនៅតែក្នុងខេត្តពោសាត់មួយរឺម៉េចដែរអ៊ុំ?

ខ៖ ទៅបាត់ដំបងដែរ ទៅមូងនឹង

ក៖ អូ្ន!ទៅមូងហោស ចុះពេលដែរអ៊ុំទៅបាត់ដំបងនឹងគេអោយអ៊ុំធ្វើអីគេដែរអ៊ុំ?

ខ៖ ទៅបាត់ដំបងនឹងទៅធ្វើស្រែនឹង

ក៖ ទៅធ្វើស្រែហោស?

ខ៖ ទៅធ្វើស្រូវ ច្រូតស្រូវ នឹងស្ទូងស្រូវនឹងហាស

ក៖ ប៉ុន្តែពេលណុងអ៊ុំនៅអាយុប៉ុន្មានដែរអ៊ុំធំៗៗហើយមែនអ៊ុំ?

ខ៖ អាយុ16-17ឆ្នាំហើយនឹង

ក៖ អូ្!ពេលណុងចូលជាកងនារីហើយណាអ៊ុំ?

ខ៖ ចូលជាកងនារីស្រួចអីគេនឹងហើយមួយហត្ថាច្រូតតែពីនាក់ទេនឹង
បើច្រូតមិនរួចទេគេយកទៅវៃចោលហើយនឹង

ក៖ ប៉ុន្តែអ៊ុំទៅរួចណាអ៊ុំ?

ខ៖ អូ្!ខំទៅទាល់តែរួចនឹង

ក៖ មិនរួចក៏ត្រូវតែទៅដែរនឹង?

ខ៖ ក៏ត្រូវតែទៅរួចដែរនឹង

ក៖ អូ្!ចុះរបបអាហារយ៉ាងម៉េចដែរទៅអ៊ុំ?
ខ៖ របបអាហារនឹងបបរមួយវែកនឹងជួនកាលបើរាវបីវែកទឹកនឹង

ក៖
បាទអ៊ុំចុះអ៊ុំគិតថាការជំលាសរបស់អ៊ុំនឹងគិតថាកន្លែងណាដែរអ៊ុំគិតថាលំបាកជាគេដែរអ៊ុំ?

ខ៖ កន្លែងដែរពិបាកជាងគេនឹងកន្លែងទៅភ្នំនឹង

ក៖ ទៅកន្លែងភ្នំ ចុះកន្លែងភ្នំនឹងនៅខេត្តណាដែរអ៊ុំ?

ខ៖ នៅកន្លែងភ្នំនឹងនៅខេត្តពោសាត់នៅជាប់ខេត្តបាត់ដំបងនឹងហាស

ក៖ ចុះគេអោយទៅធ្វើអីគេដែរអ៊ុំ?

ខ៖ គេអោយទៅគាស់ថ្មនឹង គាស់ថ្មជីកប្រលាយវែកចុះក្រោមឡើងទៅលើហោស

ក៖ កន្លែងណុងដែរអ៊ុំពិបាកជាងគេហោណអ៊ុំ?

ខ៖ ណុងពិបាកជាងគេហើយនឹង ហើយនឹងស្ទូងស្រូវនៅម្ងងនឹង ស្ទូងច្រូតស្រូវពិបាកណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ មានស្លាប់ចោលគ្នា

ក៖ ចុះឪពុកម្ដាយរបស់អ៊ុំពេលណុងគេអោយទៅណាដែរទៅអ៊ុំ?

ខ៖ កាត់ស្លាប់បាត់ហើយនឹង

ក៖ ចឹងមានន័យថាស្លាប់មុននឹងទៀតហោសអ៊ុំ?

ខ៖ ខ្ញុំទៅបាត់ហើយនឹងមិនដឹងថាគាត់ស្លាប់ពេលណា គាត់ស្លាប់នៅនេះយើងទៅមុនបាត់ហើយនឹង

ក៖ ប៉ុន្តែពេលណុងអ៊ុំនៅឆ្ងាយពីបងប្អូនដែរ?

ខ៖ នឹងនៅឆ្ងាយដែរ

ក៖ ចឹងបងប្អូនរបស់អ៊ុំក៏នៅឆ្ងាយដែរណាអ៊ុំ?

ខ៖ នៅឆ្ងាយគ្មាននរណាដឹងមុខនរណាគេទេស្លាប់អស់រលីងហើយនឹង

ក៖ ប៉ុន្តែប្អូនរបស់អ៊ុំវិញនឹង?

ខ៖ ប្អូនរបស់ខ្ញុំនឹងមិនដឹងថានៅណាផងនឹង

ក៖ ចឹងអត់ដឹងថាគាត់ធ្វើអីទេណាអ៊ុំ?

ខ៖ អត់ដឹងទេ

ក៖ ប៉ុន្តែបងរបស់អ៊ុំនឹងគាត់បានស្លាប់នៅជំនាន់ណុងដែរ?

ខ៖ គាត់ស្លប់អត់បានមួយឆ្នាំផងនឹងអត់បានអាពតមួយឆ្នាំផងបានស្លាប់ទៅ

ក៖
ចុះពេលដែរដាច់ពលពតនឹងអ៊ុំមានការលំបាកអីគេខ្លះដែរពេលណុងដាច់ពលពតភ្លាមៗ យើងនៅក្រ ទាំងអស់គ្នាមែនទេអ៊ុំ?

ខ៖  ក្រទាំងអស់តែគ្នានឹងហើយយើងគោះស្រងៃយកមកស៊ីនឹង
អត់ស្រូវទៅគោះស្រងៃយកមកស៊ីទៅ ដល់ពេលដែរឈើនៅហើមនៅឡើយនឹងហាស

ក៖  បាទអ៊ុំចឹង?

ខ៖  ហើយបានបងយកទៅដេកពេទ្យនៅពោសាត់
ដល់ពេលដែរដេកពេទ្យបានជាមកនឹងជានៅពេទ្យ
នឹងទៅធ្វើការងារនៅពេទ្យនឹងតែម្តងនឹង

ក៖  អូ៎!ចឹងហោសអ៊ុំ?

ខ៖  នឹងគាត់យកចូលទៅធ្វើពេទ្យនឹងតែម្តងនឹង

ក៖  ប៉ុន្តែពេលណុងអ៊ុំនៅជុំជាមួយប្អូនរបស់អ៊ុំវិញហើយណអ៊ុំ?

ខ៖  ជុំគ្នាប្អូននៅដេកផ្ទះសំរាប់ខ្ញុំមកដេកពេទ្យពោសាត់នឹង

ក៖  ប៉ុន្តែនៅជាមួយបងប្អូនដែរមែ្មួយនៅតែជាមួយប្អូនទេអ៊ុំ?

ខ៖  នៅជាមួយមីមានឹងប៉ុន្តែមីងបានស្លាប់អស់ហើយឥឡូវនឹងហោស

ក៖  បាទអ៊ុំចុះរហូតមកដល់ពេលណាដែរអ៊ុំគិតថាអ៊ុំធូរហាសហើយដែរអ៊ុំសប្បាយហាស
ជាពេលដែរអ៊ុំ សប្បាយហាសពេលណុងហាសអ៊ុំ?

ខ៖  នៅឆ្នាំ2000អីនឹងប៉ុន្តែនៅក្រោមនឹងបន្តិចនឹងនៅឆ្នាំ1998អីនឹងគ្រាន់តែបានធូរបន្តិចនឹង
ហើយដល់ពេលនឹងរវល់តែឈឺកូន ឈឺប្តីនឹងចាញ់កូនអីនឹងណាស់
ចាញ់ប្តីទៅបាត់ដំបងនឹងចាញ់ទៀត នឹងហាស

ក៖  បាទអ៊ុំ?

ខ៖  ជួបការលំបាកសព្វគ្រប់បែបយ៉ាងទៀតនឹង

ក៖  ប៉ុន្តែដូចជាអ៊ុំ ចុះពេលណាដែរអ៊ុំបានការជាមួយប្តីរបស់អ៊ុំដែរ
អាយុប៉ុន្មានដែរអ៊ុំពេលណុង?

ខ៖  អាយុ25ឆ្នាំនឹង

ក៖  អូ៎!អាយុ25ឆ្នាំហើយណអ៊ុំ?

ខ៖ ចាំ!នឹងហើយអាយុ25ឆ្នាំនឹង

ក៖ នៅឆ្នាំណាដែរអ៊ុំមានចងចាំទេអ៊ុំ?

ខ៖ ការនៅឆ្នាំ1986នឹងហាស

ក៖ នៅឆ្នាំ1986នឹងពេលដែរអ៊ុំការហើយអ៊ុំមានការលំបាកអីនៅក្នុងក្រុមគ្រួសារដែរអ៊ុំ?

ខ៖
អត់អីទេពេលណុងកាលការនឹងជាមួយប្តីនិយាយទៅការទៅហ្វបតែប្រាក់ខែជាមួយប្តីចឹងហាស

ក៖ បាទអ៊ុំចឹង?

ខ៖ នឹងហើយមិនដឹងថាមានក្រអីទេពេលណុងនោះនៅជាមួយរដ្ឋចិនហោស

ក៖
ចុះអ៊ុំឆ្លងកាត់ការលំបាកដែរអ៊ុំបានរៀបរាប់តាំងពីក្មេងពេលដាច់ពលពតហើយនឹងអ៊ុំឆ្លងកាត់វាដោយ របៀបណាដែរអ៊ុំ?

ខ៖ ឆ្លងពេលដែរពលពតនឹង

ក៖ តាំងពីក្មេងរហូតដល់ពលពតអីនឹងហាស?

ខ៖ តាំងពីក្មេងរហូតដល់ចាស់ខ្ញុំពិបាកជំនាន់ពលពតនឹងពិបាកខ្លាំងតែម្តងនឹង
ថាសឹងតែអស់ជីវិតមក ម្តងនឹងទៅតែមកដល់ឥឡូវនឹងមានការពិបាកម្តងទៀតនឹង

ក៖ ចុះអ៊ុំគិតថាបើសិនជាចង់អោយអ៊ុំលក្ខណះថាកាលពីអ៊ុំនៅក្មេងហាស
អ៊ុំធ្លាប់មានក្តីស្រម៉ៃថាពេល ដែរធំឡើងនឹងអ៊ុំចង់ធ្វើអីគេដែរទេ?

ខ៖ ចង់ធ្វើជាពេទ្យ

ក៖ អ៊ុំចង់ធ្វើជាពេទ្យប៉ុន្តែអ៊ុំធ្វើបានសំរេចហើយណអ៊ុំ?

ខ៖ ចាំ!បានហើយ

ក៖ ចុះពេលដែរជៀសពីពេទ្យនឹងអ៊ុំមានចង់ធ្វើអីទៀតទេអ៊ុំ?

ខ៖ ដូចជាមិនចង់គ្រូបង្រៀនក៏មិនចង់អីក៏មិនចង់ដែរនឹង

ក៖
អូ៎!បាទចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរ អ៊ុំ?

ខ៖
ផ្ដែផ្ដាំអោយកូនចៅជំនាន់ក្រោយៗៗនឹងខំរៀនសូត្រអោយបានពូកែអោយបានទានសម័យជឿនលឿននឹងគេ នឹងហាស

ក៖ អូ៎!ដោយសារតែសម័យឥឡូវនឹងជាសម័យជឿនលឿន?

ខ៖
អោយអភិវឌ្ឍន៍នឹងជឿនលឿននឹងអោយជៀសផុតពីអាគ្រឿងញៀនអីនឹងអោយអស់នឹងទៅ ខំធ្វើការនឹងខំរៀនសូត្រអោយបានចេះដឹងហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ អោយជៀសផុតពីគ្រឿងអបាយមុខផ្សេងៗៗនឹងហាស មានគ្រឿងស្រវឹង គ្រឿងញៀនអីសព្វបែប យ៉ាងនឹងហាស

ក៖ អូ៎!មានអីដែរអ៊ុំចង់ផ្ដែផ្ដាំអីផ្សេងពីនឹងទៀតអត់អ៊ុំ?

ខ៖ គ្មានអីផ្ដែផ្ដាំផ្សេងមិនដឹងថាផ្ដែផ្ដាំម៉េចទៀត
មានអីមានតែជូនពរអោយកូនចៅជំនាន់ក្រោយនឹងយល់
ដឹងពីការរស់នៅរបស់សង្គមជាតិនឹង
ថាឥឡូវនឹងមានការជឿនលឿនយ៉ាងម៉េចហើយសម័យមុននឹង
យ៉ាងម៉េចអោយចេះថ្លឹងថ្លែងនឹងអោយមើលហាសណាស់អោយកូនចៅជំនាន់ក្រោយនឹង
អោយដឹងពី ការពិតនឹងហាស
ថាពីមុននឹងពិបាកណាស់តែឥឡូវនឹងបានមកដល់សព្វថ្ងៃនេះវាបានគេចផុតពីរបប
អស់នោះហើយអោយកូនចៅខំប្រឹងទៅណាស់

ក៖ បាទអ៊ុំបាទអ៊ុំ?

ខ៖ ចា៎!អោយខំប្រឹងប្រែងទៅនឹង

កៈ  បាទមានអីផ្សេងទៀតអត់អ៊ុំ?

ខៈ  អត់មានអីផ្សេងទេនឹង

កៈ  ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ
ហើយការសំភាសន៍ទាំង
អស់នេះដែរខ្ញុំបាននិយាយជាមួយអ៊ុំខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុង
វេបសាយរបស់សាលា ដើម្បីដំកល់ទុកអោយអ៊ុំចឹងហាសអ៊ុំ បាទចឹងអរគុណច្រើនអ៊ុំ៕៕៕